សួស្តីអ្នកទាំងអស់គ្នា បាទ ជួបគ្នាម្តងទៀតហើយ ហើយនៅក្នុងថ្ងៃនេះ
យើងនឹងនិយាយអំពីការក្រោកពីគេង ដើម្បីទៅធ្វើការ។ បាទ
អញ្ចឹងយើងក្រឡេកមកមើលរូបភាពទាំងអស់គ្នាតែម្តង។

នៅក្នុងរូបភាពទី ១ បាទ នៅក្នុងរូបភាពទី ១ យើងឃើញថាមាននារីម្នាក់ ឬក៏ស្ត្រីម្នាក់ បាទ
គាត់អាយុប្រហែលជា ២៥ ឆ្នាំ អញ្ចឹងគាត់កំពុងតែគេងនៅលើគ្រែមួយ បាទ នារីម្នាក់នោះ
គាត់កំពុងតែគេង ដោយយើងឃើញថាគាត់គេងដោយពាក់អាវដៃវែងពណ៌លឿង បាទ
គាត់ពាក់អាវដៃវែងពណ៌លឿង គឺជាឈុតគេងរបស់គាត់ គាត់គេងនៅលើគ្រែមួយ
ដែលនៅលើគ្រែនោះគឺមានពូក មានខ្នើយ និងមានភួយ។
អញ្ចឹងគាត់គេងដោយកើយនៅលើខ្នើយរបស់គាត់ ដោយដៃរបស់គាត់ដាក់កាន់ទៅលើខ្នើយដែរ
គឺគាត់គេងផ្អៀងចំហៀង អញ្ចឹងគាត់គេងផ្អៀង បាទ ហើយគាត់ដណ្តប់ភួយ បាទ
អញ្ចឹងគាត់គេងផ្អៀងចំហៀងដោយដណ្តប់ភួយនៅលើគ្រែរបស់គាត់ ដែលនៅជិតគ្រែរបស់គាត់
ឬក៏នៅខាងក្រោយខ្នងគាត់ យើងឃើញថា មានបង្អួចមួយ
អញ្ចឹងគាត់គេងនៅក្នុងបន្ទប់គេងរបស់គាត់ ដោយបន្ទប់គេងរបស់គាត់ គឺមានបង្អួចមួយ
ដែលបង្អួចនោះគឺជាបង្អួចកញ្ចក់ ប៉ុន្តែបង្អួចនោះគឺត្រូវបានបិទ
ហើយនៅបង្អួចនោះគឺមានវាំងននចំនួន ២ អញ្ចឹងគាត់គេងដោយបិទបង្អួច
ព្រោះថាជាទូទៅនៅពេលយប់ គឺយើងតែងតែគេងដោយបិទបង្អួច បិទទ្វារជានិច្ច
ព្រោះដើម្បីការពារខ្លាចមានមនុស្សអាក្រក់ ឬក៏ចោរ ចូលលួចទ្រព្យសម្បត្តិរបស់យើង
ដូច្នេះហើយបង្អួចកញ្ចក់ គឺត្រូវតែបិទ ហើយដើម្បីឲ្យមានអាកាសធាតុល្អនៅក្នុងបន្ទប់ ឬក៏ត្រជាក់
កុំឲ្យស្អុះស្អាប់ យើងត្រូវប្រើប្រាស់ម៉ាស៊ីនត្រជាក់ ឬក៏កង្ហារ
ដូច្នេះយើងមិនត្រូវការខ្យល់អាកាសពីខាងក្រៅនោះទេនៅពេលយប់
ព្រោះប្រសិនបើយើងគេងបើកបង្អួច វាអាចនឹងមានគ្រោះថ្នាក់ ឬក៏បាត់បង់ទ្រព្យសម្បត្តិរបស់យើង
ដោយសារមានមនុស្សអាក្រក់ចូលនៅក្នុងបង្អួចរបស់យើង។ អញ្ចឹងនៅក្នុងរូបភាពនេះ
គឺនារីម្នាក់នោះ គេងដោយបិទបង្អួចកញ្ចក់។ អញ្ចឹងកញ្ចក់អាចធ្វើឲ្យមានពន្លឺឆ្លងកាត់បាន ដូច្នេះ
បើគាត់បិទកញ្ចក់ ទោះបីជាគាត់បិទកញ្ចក់ក៏ដោយ
ក៏ពន្លឺនៅតែអាចឆ្លងកាត់ចូលបន្ទប់របស់គាត់បានដូច្នេះដែរ អញ្ចឹងនៅពេលដែលគាត់បើកបង្អួច
គាត់បិទបង្អួច ហើយនិងគាត់បើកវាំងនន គឺបានន័យថានៅពេលព្រឹក គឺនឹងភ្លឺបន្ទប់គាត់
ព្រោះ[ព្រះអាទិត្យ] ពន្លឺព្រះអាទិត្យនឹងចាំងចូលបន្ទប់គាត់ជាក់ជាមិនខាន។
អញ្ចឹងគាត់គេងដោយបិទបង្អួចកញ្ចក់ ប៉ុន្តែបើកវាំងនន ហើយនៅក្បែរគ្រែរបស់គាត់នោះវិញ
គឺមានតុចំនួនមួយ អញ្ចឹងកូនតុតូចមួយ បាទ កូនតុនោះគឺមានថតចំនួនមួយផងដែរ
អញ្ចឹងតុគាត់នោះ គាត់ តុតូច ហើយមានថតតុមួយ ដែលថតតុនោះ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

គឺគេប្រើប្រាស់សម្រាប់ដាក់របស់របរបន្តិចបន្តួច ដូចជាទូរស័ព្ទដៃ ឬក៏ឆ្នាំងសាកទូរស័ព្ទ ឬក៏កូនសៀវភៅនានា អញ្ចឹងគេអាចដាក់នៅក្នុងថតតុនោះបាន បាទ ហើយនៅលើតុនោះ បាទ នៅលើតុនោះ គឺមាននាឡិកាឌីជីថលមួយ អញ្ចឹងនាឡិកាឌីជីថលនេះ គឺជានាឡិកាមួយសម្រាប់ឲ្យគាត់មើលម៉ោងបាន អញ្ចឹងគាត់ដាក់នាឡិកានៅលើតុក្បែរគ្រែគេងរបស់គាត់ ដោយនាឡិកានោះ គាត់ដាក់ឲ្យកំណត់ម៉ោងរោទ៍ទៀតផង បាទ នៅក្នុងរូបភាពនេះ យើងឃើញថា នាឡិកាកំពុងតែរោទ៍នៅម៉ោង ៧ ព្រឹក។ អញ្ចឹងបានន័យថា នារីម្នាក់នោះ គាត់ដាក់កំណត់ឲ្យនាឡិការោទ៍ម៉ោង ៧ ព្រឹក ដើម្បីដាស់គាត់ឲ្យភ្ញាក់ បាទ ជាទូទៅយើងនឹងប្រើប្រាស់នាឡិការោទ៍ដើម្បីកំណត់ដាស់ឲ្យយើងភ្ញាក់ពីគេង។

នៅក្នុងរូបភាពទី ២ នៅក្នុងរូបភាពទី ២ នារីម្នាក់នោះបានភ្ញាក់ពីគេង បាទ បានភ្ញាក់ពីគេង ហើយគាត់ក៏អង្គុយនៅលើគ្រែដោយពត់ខ្លួន។ អញ្ចឹងនារីម្នាក់នោះបានស្លៀកឈុតគេងរបស់គាត់ គឺមានអាវដៃវែងពណ៌លឿង ខោជើងវែងពណ៌លឿងដែរ ហើយគាត់បានងើបចេញពីគ្រែរបស់គាត់ ដោយអម្បាញ់មិញគាត់គេងនៅលើខ្នើយ ឥឡូវនេះគាត់ងើបអង្គុយនៅលើគ្រែ បាទ ហើយគាត់ស្លៀកខោជើងវែងពណ៌លឿង អាវដៃវែងពណ៌លឿង។ គាត់បានអង្គុយឡើង ហើយលើកដៃមួយចំហៀងឡើងលើ បាទ ដៃមួយខាង ឬក៏ម្ខាង ឬក៏មួយចំហៀង បាទ គាត់លើកឡើងលើ ដៃម្ខាងទៀត គាត់យកមកដាក់ត្រឹមមាត់របស់គាត់ ហើយស្ងាប ហើយគាត់ធ្វើកាយវិការដើម្បីពត់ខ្លួន អញ្ចឹងបន្ទាប់ពីភ្ញាក់ពីគេង ជាទូទៅ យើងតែងតែអង្គុយពត់ខ្លួន ដើម្បីឲ្យថាមានអារម្មណ៍ស្រស់ស្រាយបន្ទាប់ពីភ្ញាក់ពីគេង ដូច្នេះហើយនារីម្នាក់នេះ គាត់កំពុងតែពត់ខ្លួន ហើយនាឡិការបស់គាត់គឺរោទ៍នៅម៉ោង ៧ ដដែល។ អញ្ចឹងគាត់ងើបដោយសារតែ [...] សំឡេងនៃនាឡិការោទ៍។

នៅក្នុងរូបភាពទី ៣ នៅក្នុងរូបភាពទី ៣ យើងឃើញថា បន្ទាប់ពីនារីនោះពត់ខ្លួនហើយ បាទ គាត់អង្គុយនៅលើគ្រែដដែល ក៏ប៉ុន្តែគាត់បានបញ្ចប់ការពត់ខ្លួនរបស់គាត់ហើយ ហើយគាត់ឱនមកបិទនាឡិការោទ៍របស់គាត់ អញ្ចឹងជាធម្មតា នាឡិការោទ៍ ប្រសិនបើយើងមិនបិទទេ គឺវានឹងរោទ៍រហូត បាទ វានឹងធ្វើឲ្យមានសំឡេងរំខាននៅក្នុងផ្ទះ ព្រោះថានាឡិការោទ៍គឺមានសំឡេងខ្លាំង ដែលអាចដាស់យើងឲ្យភ្ញាក់ពីដំណេកបាន អញ្ចឹងនៅពេលដែលយើងភ្ញាក់ហើយ យើងត្រូវបិទនាឡិការោទ៍វិញ ព្រោះថាបើយើងមិនបិទ វានឹង[សំឡេងប្រើ] វានឹងឮសំឡេងរំខាននៅក្នុងផ្ទះយើងតែម្តង អញ្ចឹងវាពិតជារំខានខ្លាំងណាស់។ នៅក្នុងប្រទេសកម្ពុជា ជាទូទៅ យើងឃើញថា មានភាពខុសគ្នាមួយចំនួន រវាងអ្នករស់នៅទីក្រុង ជាមួយនឹងអ្នករស់នៅជនបទ បាទ ចំពោះការក្រោកពីគេង

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ព្រោះថាប្រសិនបើយើងនិយាយអំពីអ្នករស់នៅជនបទ គឺគាត់តែងតែក្រោកពីគេងពីព្រលឹម ឬក៏ពីព្រឹកជាងអ្នកនៅទីក្រុង ព្រោះថាអ្នកនៅជនបទ គាត់ងើបពីគេង ឬក៏ក្រោកពីគេង នៅម៉ោង ៥ ព្រឹក បាទ គាត់ក្រោកពីគេងនៅម៉ោង ៥ ព្រឹក ហើយឬក៏ម៉ោង ៦ ព្រឹក បាទ ព្រោះថាគាត់ជាកសិករ ដូច្នេះគាត់ត្រូវទៅ ក្រោកទៅស្រែ ឬក៏ទៅចំការរបស់គាត់ពីព្រលឹមបន្តិច ដើម្បីឲ្យមេឃត្រជាក់ ទាន់មេឃត្រជាក់ បាទ ប៉ុន្តែចំណែកឯអ្នករស់នៅទីក្រុងវិញ គឺគាត់ធ្វើការងារ ប្រកបការងារនៅក្នុងក្រុមហ៊ុន ឬក៏ប្រកបការងារនៅក្នុងសាលា ឬក៏ស្ថាប័នផ្សេងៗ អញ្ចឹងម៉ោងការងាររបស់គាត់ គឺអាចចូលម៉ោង ៧ ឬម៉ោង ៨ ដូច្នេះហើយ អ្នកដែលរស់នៅទីក្រុង គាត់គេងយូរជាងអ្នកនៅតាមជនបទ គឺគាត់អាចគេងដល់ម៉ោង ៧ ឬម៉ោង ៨ បាន។ ចំពោះការភ្ញាក់ពីគេងទៀតសោតក៏ខុសគ្នាដែរ គឺអ្នករស់នៅជនបទគាត់គេង គាត់ភ្ញាក់ពីគេង ដោយសារតែការស្ដាប់សំឡេងសត្វ អញ្ចឹងអ្នកនៅជនបទ គាត់មិនសូវប្រើប្រាស់នាឡិការោទ៍ប៉ុន្មាននោះទេ គឺគាត់ នៅពេលណាដែលគាត់ឮសូរសំឡេងសត្វមាន់រងាវ គឺគាត់នឹងភ្ញាក់ ព្រោះថាមាន់រងាវ ជាទូទៅ នៅពេលព្រលឹមម៉ោង ៥ គឺមាន់រងាវ។ អញ្ចឹងគាត់នឹងភ្ញាក់តាមសំឡេងមាន់រងាវនោះឯង។ ប៉ុន្តែអ្នករស់នៅទីក្រុង គឺមិនមានចិញ្ចឹមសត្វច្រើននោះទេ ដូច្នេះគាត់ត្រូវការដាក់នាឡិការោទ៍ ដើម្បីឲ្យគាត់ដឹងថាម៉ោងប៉ុន្មាន ឬក៏ដើម្បីឲ្យគាត់ភ្ញាក់ពីដំណេក។ អញ្ចឹងនៅក្នុងរូបភាពនេះ គឺនារីម្នាក់នេះ គឺគាត់រស់នៅទីក្រុង បាទ គាត់រស់នៅទីក្រុង ដោយសារតែគាត់ប្រើប្រាស់នាឡិការោទ៍ ដើម្បីដាស់ឲ្យគាត់ភ្ញាក់ពីដំណេក។

បាទ ចូលដល់រូបភាពទី ៤ នៅក្នុងរូបភាពទី ៤ យើងឃើញថា បន្ទាប់ពីនារីម្នាក់នោះ គាត់បិទនាឡិការោទ៍គាត់ហើយ បាទ អញ្ចឹងគាត់បិទនាឡិការោទ៍ ដើម្បីកុំឲ្យមានសំឡេងរំខាននៅក្នុងផ្ទះគាត់ បន្ទាប់ពីគាត់បិទនាឡិការោទ៍ហើយ នារីម្នាក់នោះ គាត់បានដើរចេញពីកន្លែងគ្រែគេងរបស់គាត់ អញ្ចឹងជាទូទៅ បន្ទាប់ពីយើងភ្ញាក់ពីគេង យើងត្រូវរៀបចំកន្លែងគេងរបស់យើងឲ្យមានសណ្ដាប់ធ្នាប់ បាទ អញ្ចឹងនៅក្នុងរូបភាពនេះ នារីម្នាក់នោះ បាទ បន្ទាប់ពីគាត់ភ្ញាក់ពីគេងហើយ គាត់ត្រូវរៀបចំកន្លែងគេងរបស់គាត់ ដោយរៀបចំខ្នើយនិងភួយឲ្យមានសណ្ដាប់ធ្នាប់ បន្ទាប់មកគាត់ក៏បានដើរចេញពីគ្រែគេងរបស់គាត់ បាទ ព្រោះថានៅពេលដែលយើងភ្ញាក់ពីគេង យើងមិនត្រូវអង្គុយនៅលើគ្រែយូរពេកនោះទេ វានាំឲ្យយើងខាតពេលវេលា ព្រោះថាយើងត្រូវប្រញាប់រៀបចំខ្លួនដើម្បីទៅសាលា ឬក៏ទៅធ្វើការទៀត។ អញ្ចឹងភ្លាមៗ បន្ទាប់ពីភ្ញាក់ពីគេង យើងត្រូវក្រោកចេញ ហើយរៀបចំកន្លែងគេងរបស់យើងឲ្យមានសណ្ដាប់ធ្នាប់ បន្ទាប់មកយើងត្រូវទៅបន្ទប់ទឹក ដើម្បីងូតទឹក។ អញ្ចឹងនៅក្នុងរូបភាពទី ៤ នេះ នារីម្នាក់នោះ គាត់បានដើរចេញពីគ្រែគេងរបស់គាត់ ហើយដើរសំដៅទៅបន្ទប់ទឹក។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ចូលដល់រូបភាពទី ៥ នៅក្នុងរូបភាពទី ៥ នារីដដែលនោះ គាត់បានដើរចូលក្នុងបន្ទប់ទឹករបស់គាត់ បាទ គាត់ភ្ញាក់ពីគេង ហើយគាត់ដើរចូលក្នុងបន្ទប់ទឹករបស់គាត់ ដោយបន្ទប់ទឹករបស់គាត់ គាត់ យើងឃើញថា មានដូចជាឡាបូលាងដៃ បាទ ឡាបូលាងដៃមួយ មានក្បាលរ៉ូប៊ីនេ ឬក៏ក្បាលម៉ាស៊ីនទឹកមួយ ដែលមានពណ៌ខៀវ នៅលើឡាបូលាងដៃនោះ ហើយនៅពីលើក្បាលម៉ាស៊ីនទឹកនោះ គឺយើងឃើញមានកូនទូតូចមួយ បាទ កូនទូតូចនោះ គឺជាទូសម្រាប់ដាក់សម្ភារៈបន្ទប់ទឹក ដូចជាច្រាសដុសធ្មេញ សាប៊ូដុសខ្លួន សាប៊ូកក់សក់ជាដើម។ អញ្ចឹងយើងប្រើប្រាស់កូនទូតូចមួយ ដើម្បីដាក់សម្ភារៈទាំងនោះប្រើប្រាស់នៅក្នុងបន្ទប់ទឹក។ បន្ទប់ទឹករបស់គាត់គឺមានកញ្ចក់មួយ ប៉ុន្តែកញ្ចក់ កញ្ចក់បង្អួចនោះ គឺនៅខ្ពស់ បាននិយថាខ្ពស់ផុតក្បាលរបស់គាត់ អញ្ចឹង យើង បើយើងដាក់កញ្ចក់ទាបពេក គឺគេអាចមើលឃើញយើងនៅពេលដែលយើងងូតទឹក ដូច្នេះយើងត្រូវដាក់ឲ្យខ្ពស់ពីខ្លួន ដើម្បីការពារកុំឲ្យគេមើលឃើញ។ នៅក្នុងរូបភាពនេះ គឺនារីម្នាក់នោះ គាត់បានដើរចូលក្នុងបន្ទប់ទឹករបស់គាត់ ដោយដើរសំដៅទៅរកឡាបូលាងដៃ។

ចូលដល់រូបភាពទី ៦ នៅក្នុងរូបភាពទី ៦ យើងឃើញថា បន្ទាប់ពីនារីម្នាក់នោះ គាត់ដើរចូលក្នុងបន្ទប់ទឹកគាត់រួចរាល់ហើយ គាត់បានបើកទូកញ្ចក់ឬក៏កូនទូរបស់គាត់ ដើម្បីយកថ្នាំដុសធ្មេញនិងច្រាសដុសធ្មេញចេញមក។ អញ្ចឹងនៅពេលដែលភ្ញាក់ពីគេងហើយ យើងត្រូវការដុសធ្មេញ ដុសសម្អាតធ្មេញរបស់យើង ដើម្បីយកកម្ទេចកម្ទីចេញពីធ្មេញរបស់យើង ព្រោះថាពេលល្ងាច គឺយើងញ៉ាំអាហារពេលល្ងាចជាច្រើន អញ្ចឹងកម្ទេចកម្ទីនឹងនៅជាប់ធ្មេញរបស់យើងជាក់ជាពុំខាន។ ដូច្នេះនៅក្នុងរូបភាពនេះ នារីម្នាក់នោះ គាត់បានច្របាច់ថ្នាំដុសធ្មេញដាក់នៅលើច្រាសដុសធ្មេញរបស់គាត់ អញ្ចឹងថ្នាំដុសធ្មេញ ប្រអប់ថ្នាំដុសធ្មេញរបស់គាត់គឺមានពណ៌ស ចំណែកឯថ្នាំដុសធ្មេញគឺមានពណ៌បៃតងនិងលាយស ហើយច្រាសដុសធ្មេញរបស់គាត់គឺមានពណ៌ក្រហម។ អញ្ចឹងគាត់បានច្របាច់ថ្នាំដុសធ្មេញមួយចំនួន ដាក់ទៅលើច្រាសដុសធ្មេញរបស់គាត់ បាទ គាត់ច្របាច់ច្រាសដុសធ្មេញថ្នាំដុសធ្មេញ ទៅលើច្រាសដុសធ្មេញ ដើម្បី សម្រាប់ធ្វើការដុសធ្មេញគាត់ អញ្ចឹងគាត់ដុសធ្មេញជារៀងរាល់ព្រឹកតែម្តង ព្រោះថាការដុសធ្មេញ គឺធ្វើឲ្យយើងបំបាត់ក្លិនមាត់។ អញ្ចឹងពេលដែលយើងក្រោកពីគេង គឺកម្ទេចកម្ទីកាកសំណល់ ដែលយើងញ៉ាំអាហារពីពេលល្ងាចនោះនៅតោងស្អិតជាប់ធ្មេញរបស់យើង ដូច្នេះវានឹងធ្វើឲ្យមានដង្កូវស៊ីធ្មេញ ឬក៏មានក្លិនមាត់ ប្រសិនបើយើងមិនបានដុសធ្មេញនោះទេ។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

នៅក្នុងរូបភាពទី ៧ នៅក្នុងរូបភាពទី ៧ បន្ទាប់ពីនារីម្នាក់នោះ
គាត់ច្របាច់ថ្នាំដុសធ្មេញដាក់លើច្រាសដុសធ្មេញរបស់គាត់ហើយ
នារីម្នាក់នោះបានយកច្រាសដុសធ្មេញមកដុសធ្មេញរបស់គាត់ អញ្ចឹងគាត់ដុសធ្មេញ
ដុសសម្អាតធ្មេញរបស់គាត់យ៉ាងយកចិត្តទុកដាក់ គឺ គឺធ្វើតាមក្បួនដុសធ្មេញ ដែលគាត់ធ្លាប់បានរៀន
គឺការដុសពីលើចុះក្រោម ពីក្រោមឡើងលើ ពីឆ្វេងទៅស្តាំ អញ្ចឹងគាត់ដុសម្តងមួយៗ
បានន័យថាធ្មេញរបស់គាត់ គាត់ដុសចុះឡើងៗ ហើយយើងឃើញថាថ្នាំដុសធ្មេញតែងតែមានពពុះ
អញ្ចឹងនៅពេលដែលគាត់ដុស គឺមានពពុះចេញពីក្នុងមាត់គាត់យ៉ាងច្រើន
ដូច្នេះពពុះនេះវាមិនមែនជាពពុះគ្រោះថ្នាក់នោះទេ គឺជាពពុះនៃថ្នាំដុសធ្មេញ
ព្រោះថាថ្នាំដុសធ្មេញដែលយើងប្រើប្រាស់ គឺផ្សំពីសារធាតុជាច្រើន ដែលមានក្លិនប្រហើរ
ឬក៏ការពារដង្កូវស៊ីធ្មេញ អញ្ចឹងវានឹងធ្វើ[...] ធ្វើការសម្អាតនូវកាកសំណល់ផ្សេងៗ
ដែលនៅជាប់ធ្មេញនិងនៅក្នុងមាត់របស់យើង ដូច្នេះហើយ គាត់ដុសធ្មេញដើម្បីសម្អាត
ហើយបំបាត់ក្លិនមាត់របស់គាត់ក្រោយពីក្រោកពីគេង បាទ។ អញ្ចឹងមិនត្រឹមតែដុសធ្មេញនោះទេ
នារីម្នាក់នោះ គាត់ដុសអណ្តាតគាត់ផងដែរ ដូច្នេះការដុសសម្អាតធ្មេញ មាត់ធ្មេញ
គឺយើងត្រូវការដុសទាំងអណ្តាត ទាំងធ្មេញ ដើម្បីកម្ចាត់ក្លិនមាត់និងកាកសំណល់ផ្សេងៗ។

ចូលដល់រូបភាពទី ៨ អញ្ចឹងនៅក្នុងរូបភាពទី ៨ បន្ទាប់ពីគាត់ដុសធ្មេញរួច បាទ
អញ្ចឹងគាត់ដកច្រាសដុសធ្មេញចេញពីក្នុងមាត់របស់គាត់ហើយ ហើយគាត់មានកាន់កែវទឹកមួយ បាទ
គាត់មានកាន់កែវទឹកមួយ ដែល យើងឃើញថា គាត់កំពុងតែងើយមុខឡើងលើបន្តិច
ហើយមានទឹកនៅក្នុងមាត់របស់គាត់ អញ្ចឹងគាត់ត្រូវខ្ពុរមាត់ចេញ បាទ
អញ្ចឹងបានន័យថាគាត់ដាក់ទឹកក្នុងកែវ ហើយគាត់ខ្ពុរមាត់ចេញ បានន័យថា
នៅពេលដែលដុសធ្មេញរួច យើងត្រូវតែខ្ពុរមាត់ចេញនូវថ្នាំដុសធ្មេញ ដែលនៅក្នុងមាត់របស់យើង
ឬក៏ខ្ពុរពពុះថ្នាំដុសធ្មេញចេញ។ ព្រោះថាថ្នាំដុសធ្មេញដែលនៅក្នុងមាត់ បន្ទាប់ពីយើងដុសធ្មេញរួច
គឺជាកាកសំណល់ ហើយនិងជាវត្ថុកខ្វក់ ដូច្នេះយើងត្រូវខ្ជាក់ចេញឲ្យអស់ ចេញពីមាត់របស់យើង
ហើយខ្ពុរវាឬក៏លាងសម្អាតមាត់យើងដោយទឹកស្អាត ធ្វើដូចនារីម្នាក់នេះដែលនៅក្នុងរូបភាព
គឺគាត់ដាក់ទឹកចូលក្នុងមាត់ បន្ទាប់មកគឺគាត់ខ្ពុរ។ អញ្ចឹងគាត់ការលាងសម្អាតមាត់ បន្ទាប់ពីដុសធ្មេញ
យើងហៅថាការខ្ពុរមាត់។ បាទ គាត់ខ្ពុរមាត់
ដោយគាត់យកទឹកទៅខ្ពុរមាត់ទាំងឆ្វេងទាំងស្តាំនៅក្នុងមាត់របស់គាត់ទាំងអស់
ហើយទឹកដែលគាត់ខ្ពុរនោះ គាត់ត្រូវខ្ជាក់ចេញមកក្រៅទាំងអស់
គឺគាត់មិនត្រូវលេបចូលក្នុងពោះនោះទេ ព្រោះការលេបទឹកកខ្វក់ចូលក្នុងពោះបែបនេះ
អាចធ្វើឲ្យយើងមានជំងឺបាន។ បាទ ហើយបន្ទាប់ពីគាត់ខ្ពុរមាត់ហើយ
គាត់ក៏បានលាងច្រាសដុសធ្មេញរបស់គាត់ផងដែរ។ អញ្ចឹងនៅពេលដែលយើងដុសធ្មេញហើយ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

យើងមិនត្រឹមតែលាងមាត់របស់យើងនោះទេ
ច្រាសដុសធ្មេញរបស់យើងក៏ត្រូវតែលាងសម្អាតផងដែរ បើមិនដូច្នេះទេ
សារធាតុកខ្វក់ដែលនៅជាមួយនឹងថ្នាំដុសធ្មេញ ឬក៏នៅជាមួយនឹងធ្មេញរបស់យើង
ដែលជាប់នឹងច្រាសដុសធ្មេញ វានឹងកកើតជាបាក់តេរី ឬក៏ជាមេរោគ ធ្វើឲ្យយើងមានជំងឺផ្សេងៗ
នៅពេលដែលយើងយកច្រាសនោះមកដុសម្តងទៀត។
អញ្ចឹងយើងត្រូវសម្អាតច្រាសដុសធ្មេញឲ្យបានស្អាតមុននឹងយកទៅទុក។

ចូលដល់រូបភាពទី ៩ នៅក្នុងរូបភាពទី ៩ យើងឃើញថា បន្ទាប់ពីដុសធ្មេញរួច នារីម្នាក់នោះ
គាត់ក៏បានងូតទឹក បាទ អញ្ចឹងការងូតទឹករបស់គាត់ គឺងូតដោយទឹកផ្កាឈូក បាទ ជាទូទៅ
នៅក្នុងទីក្រុង គឺយើងប្រើប្រាស់ទឹកផ្កាឈូកនៅក្នុងបន្ទប់ទឹករបស់យើង
ក៏ប៉ុន្តែបើសិនជានៅតាមទីជនបទវិញ ការងូតទឹក
គឺគាត់មិនមានទឹកម៉ាស៊ីនប្រើប្រាស់គ្រប់គ្រាន់នោះទេ ដោយនៅក្នុងប្រទេសកម្ពុជា
ការប្រើប្រាស់ទឹកម៉ាស៊ីន ភាគច្រើនគឺសម្បូរតែនៅក្នុងទីក្រុងតែប៉ុណ្ណោះ ប៉ុន្តែសម្រាប់នៅទីជនបទ
គឺយើងប្រើប្រាស់ទឹកពាងឬក៏ទឹកអាង ដោយបានទទួលមកពីទឹកភ្លៀង អញ្ចឹងអ្នកនៅជនបទ
គាត់ប្រើប្រាស់ទឹកភ្លៀង នៅពេលដែលភ្លៀងមក គាត់ត្រងភ្លៀងទុកដាក់ក្នុងពាងឬក៏ក្នុងអាង
បន្ទាប់មកគាត់យកទឹកភ្លៀងនោះឲ្យមកប្រើប្រាស់ ដោយគាត់មានផ្តិលមួយ
គាត់យកផ្តិលចាក់លើខ្លួនរបស់គាត់ដើម្បីងូតទឹក ក៏ប៉ុន្តែសម្រាប់អ្នកនៅទីក្រុង
គឺគេប្រើប្រាស់ទឹកម៉ាស៊ីន ដូច្នេះគេគ្រាន់តែបើកក្បាលរ៉ូប៊ីនេទឹក ទឹកនឹងចេញមកភ្លាមតែម្តង
ដូចនៅក្នុងរូបភាពនេះ នារីម្នាក់នោះ គាត់បានងូតទឹកដោយប្រើប្រាស់ក្បាលទឹកម៉ាស៊ីន
គឺជាទឹកផ្កាឈូក។ គាត់ងូតទឹកបណ្តើរ ដុសសាប៊ូបណ្តើរ និងកក់សក់បណ្តើរ។
អញ្ចឹងក្នុងការសម្អាតខ្លួន ការងូតទឹក យើងត្រូវប្រើប្រាស់សាប៊ូដើម្បីដុសខ្លួនផងដែរ
ព្រោះថាពេញមួយថ្ងៃដែលយើងធ្វើការហើយ មេរោគនឹងតោងជាប់ខ្លួនយើង ដូច្នេះ
នៅពេលដែលយើងគេង យើងងូតទឹកសម្អាតខ្លួនបានមួយសា
ក៏ប៉ុន្តែនៅពេលដែលយើងក្រោកពីគេង គឺនឹងមានញើស បានន័យថាពេលដែលយើងគេង
ក៏យើងបែកញើសដែរ អញ្ចឹងធ្វើឲ្យខ្លួនយើងប្រឡាក់ ឬក៏ស្អិតខ្លួន
ឬក៏មានមេរោគតោងនៅជាប់ខ្លួនយើងជាក់ជាមិនខាន អញ្ចឹងនៅពេលដែលយើងងូតទឹក
យើងត្រូវសម្អាតខ្លួនយើងឲ្យបានស្អាត ដោយដុសខ្លួនយើងជាមួយនឹងសាប៊ូ បាទ
ហើយកក់សក់យើងផងដែរ ព្រោះថាសក់របស់យើងត្រូវសម្អាតយ៉ាងតិចមួយសប្តាហ៍
ឬក៏មួយអាទិត្យបីដង អញ្ចឹងមួយសប្តាហ៍មានរយៈពេល ៧ ថ្ងៃ
ដូច្នេះយើងត្រូវអនុវត្តតាមក្បួនអនាម័យ គឺមួយសប្តាហ៍យើងត្រូវកក់សក់យ៉ាងតិចក៏បីដងដែរ
ដើម្បីកម្ចាត់ធាតុកខ្វក់ចេញពីសក់ក្បាលរបស់យើង ដើម្បីឲ្យយើងមានអារម្មណ៍ថាស្រស់ថ្លា

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

និងការពារការរមាស់ក្បាល។ អញ្ចឹងរូបភាពទី ៩ នេះ នារីម្នាក់នោះ គាត់បានកក់សក់របស់គាត់នឹងសាប៊ូ ហើយគាត់កំពុងដុសខ្លួនរបស់គាត់ផងដែរ នៅពេលដែលគាត់ងូតទឹក។

ចូលដល់រូបភាពទី ១០ នៅក្នុងរូបភាពទី ១០ យើងឃើញថា នារីម្នាក់នោះ បន្ទាប់ពីងូតទឹកហើយ បាទ បន្ទាប់ពីងូតទឹករួច គាត់បានយកកន្សែងមួយមកជូតខ្លួន អញ្ចឹងជាទូទៅបន្ទាប់ពីយើងងូតទឹករួច យើងត្រូវជូតខ្លួនយើងឲ្យបានស្ងួតជាមុនសិន មុននឹង[គាត់]យើងស្លៀកពាក់ខោអាវ។ អញ្ចឹងនារីម្នាក់នោះ គាត់ពុំទាន់ស្លៀកពាក់ខោអាវនោះទេ ដែលគាត់បានយកកន្សែងមួយមករុំខ្លួនរបស់គាត់ បន្ទាប់មកគាត់បានយកកន្សែងនោះមកជូតនឹងខ្លួនរបស់គាត់ ដោយជូតខ្លួនមុន បន្ទាប់មកគាត់ជូតដៃតាមក្រោយ អញ្ចឹងគាត់យកជូតកន្លែងណាដែលសើម គឺដូចជាសក់ ដូចជាខ្លួន និងដៃជើងផងដែរ ព្រោះថានៅពេលដែលយើងចេញពីបន្ទប់ទឹក បើយើងមិនជូតខ្លួនទេ ទឹកនឹងស្រក់តាមខ្លួនរបស់យើង។ អញ្ចឹងទឹកស្រក់ធ្វើឲ្យប្រឡាក់ផ្ទះ ឬក៏សើមនៅក្នុងផ្ទះ ហើយអាចមានគ្រោះថ្នាក់នៅពេលដែលយើងដើរជាន់ទឹកនោះ ព្រោះវាអាចមិនដើរឲ្យយើងរអិលដួលបាន។ ដូច្នេះយើងត្រូវជូតខ្លួនឲ្យស្ងួតជាមុនសិន មុននឹងចេញពីបន្ទប់ទឹក ដើម្បីកុំឲ្យមានទឹកស្រក់ ឬក៏រអិលដួល នៅពេលដែលយើងចេញពីបន្ទប់ទឹក។ ហើយក៏វាជាការសម្អាតខ្លួនមួយដែរ ព្រោះថានៅពេលដែលយើងងូតទឹករួច យើងត្រូវជូតសម្អាតខ្លួនឲ្យបានស្ងួត ដើម្បីកុំឲ្យសើម ឬក៏ទទឹកនូវខោអាវរបស់យើង។

ចូលដល់រូបភាពទី ១១ នៅក្នុងរូបភាពទី ១១ បន្ទាប់ពីនារីម្នាក់នោះ គាត់បានជូតខ្លួនរួចហើយ គាត់ក៏បានចូលក្នុងបន្ទប់គេងរបស់គាត់វិញ។ បាទ គាត់ចូលក្នុងបន្ទប់គេងរបស់គាត់ ក៏ប៉ុន្តែគាត់មិនមែនចូលទៅគេងវិញនោះទេ ដោយគាត់បានផ្លាស់សម្លៀកបំពាក់ អញ្ចឹងគាត់កំពុងតែផ្លាស់សម្លៀកបំពាក់របស់គាត់ ដោយគាត់យកខោអាវគេង ឈុតគេងរបស់គាត់ ដែលគាត់គេងយប់នោះ គឺមានឈុតខោជើងវែងពណ៌លឿង និងអាវដៃវែងពណ៌លឿង ដាក់នៅលើគ្រែ បានន័យថាគាត់ដោះសម្លៀកបំពាក់ឈុតគេងរបស់គាត់ចេញ ដែលដាក់នៅលើគ្រែទាំងពីរ បន្ទាប់មកគាត់បានផ្លាស់សម្លៀកបំពាក់ធ្វើការងាររបស់គាត់។ ដោយគាត់យកអាវដៃវែងពណ៌ទឹកសមុទ្រ ឬក៏ពណ៌ខៀវ មកពាក់នៅលើខ្លួនរបស់គាត់ ដោយនារីម្នាក់នោះ គាត់បានស្លៀកសំពត់ជាមុន សំពត់របស់គាត់គឺមានពណ៌ស ហើយសំពត់នោះគឺត្រឹមជង្គង់។ អញ្ចឹងប្រវែងសំពត់គឺត្រឹមជង្គង់ ហើយមានពណ៌ស

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ហើយគាត់ពាក់អាវដៃវែងពណ៌ខៀវ ដោយគាត់ពាក់អាវបណ្ដើរ គាត់លើកដៃបណ្ដើរ ដើម្បីស៊កដៃបញ្ចូល បន្ទាប់មកគាត់ទាញខ្លួនអាវទម្លាក់ចុះក្រោម ដើម្បីពាក់អាវ។

ចូលដល់រូបភាពទី ១២ អញ្ចឹងនៅក្នុងរូបភាពទី ១២ បន្ទាប់ពីគាត់ផ្លាស់សម្លៀកបំពាក់រួច បានន័យថាគាត់ស្លៀកពាក់ខោអាវធ្វើការរួចរាល់ហើយ គាត់បានចេញពីបន្ទប់គេងរបស់គាត់ ដោយគាត់ដើរសំដៅមកតុមួយនៅក្នុងផ្ទះ បាទ អញ្ចឹងតុនោះគឺមានកាបូបរបស់គាត់ បាទ អញ្ចឹងកាបូបស្ពាយធ្វើការរបស់គាត់គឺមានពណ៌ទឹកក្រូច បាទ ហើយនៅលើតុនោះគឺមានអំពូលមួយ គេហៅថាអំពូលចាន អញ្ចឹងអំពូលមួយនោះ គឺដាក់បំភ្លឺនៅលើតុរបស់គាត់ ដោយគាត់បានដាក់កាបូបនៅលើនោះ។ អញ្ចឹងនារីម្នាក់នោះគឺជាមនុស្សដែលមានសណ្ដាប់ធ្នាប់ម្នាក់ បានន័យថា សម្ភារៈរបស់គាត់ដែលគាត់ត្រូវការដើម្បីទៅធ្វើការ គឺគាត់រៀបចំរួចរាល់អស់ហើយ នៅក្នុងកាបូបស្ពាយរបស់គាត់ ដូច្នេះនៅពេលដែលគាត់ផ្លាស់ខោអាវរួច គាត់ពុំចាំបាច់ដើររកសម្ភារៈ ដើម្បីទៅធ្វើការនោះទេ គាត់គ្រាន់តែមកស្ពាយនូវកាបូប ឬក៏យកកាបូបគាត់ គឺជាការស្រេចតែម្ដង ព្រោះអ្វីៗដែលគាត់ត្រូវការ គឺគាត់រៀបចំនៅក្នុងកាបូបនេះរួចជាស្រេចទៅហើយ។

នៅក្នុងរូបភាពទី ១៣ បាទ បន្ទាប់ពីនារីម្នាក់នោះ គាត់យកកាបូបគាត់ហើយ នារីម្នាក់នោះ គាត់បានដើរមកដើរបើកទ្វារ អញ្ចឹងគាត់ដើរមកបើកទ្វាររបស់គាត់ដើម្បីចេញទៅក្រៅ។ យើងឃើញថានៅក្នុងផ្ទះរបស់គាត់គឺមានកម្រាលព្រំមួយ បាទ នៅក្រោយនារីនោះ គឺមានកម្រាលព្រំមួយ កម្រាលព្រំជាទូទៅយើងដាក់នៅក្នុងផ្ទះ ដើម្បីឲ្យយើងដើរជាន់ ឬក៏ដាក់តាំងលម្អ។ អញ្ចឹងយើងក្រាលកម្រាលព្រំគឺជាសោភ័ណភាពមួយ ដើម្បី នៅក្នុងផ្ទះផងដែរ។ បាទ ហើយផ្ទះរបស់គាត់គឺតាំងលម្អដោយផ្ទាំងគំនូរមួយផ្ទាំង។ អញ្ចឹងគាត់ជាអ្នកដែលស្រឡាញ់គំនូរផងដែរ ព្រោះថាគាត់បានតាំងលម្អផ្ទាំងគំនូរនៅក្នុងផ្ទះរបស់គាត់។ ផ្ទះគាត់ក៏មានដូចជាដាំដើមឈើ គឺមានដាំដើមឈើនៅក្នុងថូផ្ការរបស់គាត់ អញ្ចឹងដើមឈើឬក៏ផ្កា គាត់ដាំនៅក្នុងថូ ហើយដាក់នៅលើជើងពានមួយ បាទ នៅលើជើងពាន ឬលើជើងទម្រ ដែលផ្ការរបស់គាត់នោះ គាត់ដាំនៅមាត់ទ្វារផ្ទះ បាទ គាត់ដាំលម្អនៅមាត់ទ្វារផ្ទះ។ អញ្ចឹងនារីម្នាក់នោះ គាត់បានបើកទ្វារផ្ទះ ដើម្បីចេញទៅក្រៅ បាទ គាត់បានបើកទ្វារផ្ទះ ទ្វាររបស់គាត់គឺបើកចូលក្នុង ហើយគាត់ដើរចេញក្រៅទៅតាមទ្វារនោះ។

ចូលដល់រូបភាពទី ១៤ នៅក្នុងរូបភាពទី ១៤ យើងឃើញថា នារីម្នាក់នោះ គាត់បានចេញពីផ្ទះរបស់គាត់ហើយ ហើយគាត់បានដើរសំដៅទៅកន្លែងធ្វើការរបស់គាត់ ដោយគាត់ដើរបណ្ដើរ យកដៃម្ខាងខ្ទប់ទៅលើកាបូបស្ពាយរបស់គាត់ដើម្បីកុំឲ្យយោល។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

អញ្ចឹងនៅពេលដែលយើងដើរ ហើយយើងស្ពាយកាបូប ជាទូទៅ យើងតែងតែខ្ទប់ ឬក៏ទប់កាបូបយើង កុំឲ្យវាយោលយោក ព្រោះថានៅពេលដែលកាបូបយោល គឺយើងពិបាកនៅក្នុងការធ្វើដំណើរ ដោយសារតែវាយោលចុះយោលឡើង អញ្ចឹងទៅ គឺ យើងនឹងពិបាកដោយសារយើងឃ្លីងឃ្លោងទៅតាមកាបូបរបស់យើង។ ដូច្នេះគាត់យកកាបូប គាត់យកដៃរបស់គាត់ទប់កាបូបដើម្បីកុំឲ្យយោល ធ្វើឲ្យគាត់ងាយស្រួលក្នុងការដើរទៅមុខ។ អញ្ចឹងយើងឃើញថា គាត់ពុំបានជិះម៉ូតូ ឬក៏ជិះស៊ីក្លូ ឬក៏ជិះឡានអីទេ ដោយសារតែគាត់មិនមានការប្រញាប់ប្រញាល់ខ្លាំងនោះទេ ហើយកន្លែងធ្វើការរបស់គាត់ ក៏នៅជិតនឹងផ្ទះរបស់គាត់ផងដែរ ដូច្នេះគាត់ដើរ គឺមានអត្ថប្រយោជន៍ផងដែរ ព្រោះថា គាត់អាចសន្សំសំចៃទៅលើការចំណាយផ្សេងៗ ដូចជាការចំណាយលើម៉ូតូឌុប ឬក៏ការចំណាយលើថ្លៃសាំងជាដើម។ ហើយគាត់ដើរនេះ គឺបានប្រយោជន៍ដល់សុខភាពរបស់គាត់ផងដែរ គឺប្រៀបដូចជាការហាត់ប្រាណអញ្ចឹង ព្រោះគាត់ពុំមានពេលហាត់ប្រាណច្រើននោះទេ ដូច្នេះហើយគាត់ដើរ គឺប្រៀបដូចជាគាត់ហាត់ប្រាណ ដើម្បីសុខភាពគាត់ផងដែរ។

នៅក្នុងរូបភាពទី ១៥ នៅក្នុងរូបភាពទី ១៥ យើងឃើញថា បន្ទាប់ពីគាត់ដើរបានបន្តិច គាត់បានមកដល់កន្លែងលក់បាយមួយ អញ្ចឹងគាត់បានជួបនឹងនារី អ្នកលក់បាយម្នាក់ បាទ ម្ចាស់តូបលក់បាយ ប៉ុន្តែហាងបាយនោះគឺជាកន្លែងលក់បាយដែលនៅតាមចិញ្ចើមផ្លូវនោះទេ ព្រោះថាគាត់នៅតាមផ្លូវទៅធ្វើការរបស់គាត់ គាត់បានចូលមកកន្លែងលក់បាយនេះ ដោយគាត់បានទិញបាយ បានន័យថាគឺជាអាហារពេលព្រឹករបស់គាត់ អញ្ចឹងយើងមានអាហារពេលព្រឹក នៅក្នុងប្រទេសកម្ពុជាគឺមានច្រើនប្រភេទផងដែរ មានដូចជាបាយស្រូប មានដូចជាបបរ មានដូចជានំបញ្ចុក និងមានដូចជាគុយទាវជាដើម ដូច្នេះជាទូទៅពួកយើងញ៉ាំបាយស្រូប បាទ មុននឹងទៅធ្វើការ ឬក៏យើងទៅដល់កន្លែងធ្វើការហើយទើបយើងញ៉ាំ។ នៅក្នុងរូបភាពនេះ គឺនារីម្នាក់នោះបានទិញបាយស្រូបមួយប្រអប់។ អញ្ចឹងបានន័យថាគាត់ខ្ចប់ គាត់ឲ្យអ្នកលក់ខ្ចប់បាយស្រូបរបស់គាត់មួយប្រអប់ ដើម្បីជាអាហារពេលព្រឹករបស់គាត់។ គាត់ពុំបានញ៉ាំនៅនឹងកន្លែងនោះទេ ដោយសារតែគាត់ត្រូវទៅធ្វើការឲ្យទាន់ម៉ោង ឲ្យទាន់ពេលវេលា។ អញ្ចឹងអ្នកលក់បានយកបាយមួយប្រអប់ ដែលគាត់ខ្ចប់រួច មកឲ្យនារីម្នាក់នោះ តាមការកុម្ម៉ង់របស់នារីម្នាក់នោះ ហើយនារីម្នាក់នោះ គាត់បានហុចលុយទៅឲ្យអ្នកលក់ផងដែរ ទៅលើថ្លៃបាយ ដែលគាត់បានទិញ។ អញ្ចឹងជាទូទៅការលក់បាយនៅតាមផ្លូវនេះ គឺយើងមានជម្រើសពីរ គឺយើងអាចអង្គុយញ៉ាំនៅកន្លែងហាងនោះតែម្តងក៏បាន យើងឲ្យគេខ្ចប់ក៏បាន ព្រោះថានៅពេលដែលគេខ្ចប់ គេនឹងមានប្រអប់ស្នោមួយ ដើម្បីខ្ចប់បាយឲ្យយើង

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

យ៉ាងមានសណ្ដាប់ធ្នាប់ទៀតផង ហើយគេមានស្លាបព្រាដាក់នៅក្នុងនោះផងដែរ
ដើម្បីឲ្យយើងងាយស្រួលញ៉ាំ ដូចនារីម្នាក់នេះ គាត់បានខ្ចប់បាយ
ដើម្បីសម្រាប់អាហារពេលព្រឹករបស់គាត់អញ្ចឹង។

នៅក្នុងរូបភាពទី ១៦ នៅក្នុងរូបភាពទី ១៦ ដោយសារតែគាត់ពុំមានពេលច្រើនក្នុងការញ៉ាំបាយ
នៅកន្លែងហាងគេនោះទេ ដូច្នេះគាត់ក៏បានយួរប្រអប់បាយនោះមកកន្លែងធ្វើការរបស់គាត់
ដោយគាត់បានយួរប្រអប់បាយនៅក្នុងថង់មួយ បាទ ដៃម្ខាងរបស់គាត់គឺស្ពាយកាបូប
ដៃម្ខាងទៀតរបស់គាត់គឺយួរថង់បាយ។ អញ្ចឹងគាត់យួរថង់បាយ ឬក៏អាហារពេលព្រឹករបស់គាត់
ដើរតាមផ្លូវទៅកន្លែងធ្វើការ ដោយបន្តដំណើរទៅមុខទៀត បាទ។ នារីម្នាក់នោះ ថ្ងៃនេះ
គាត់មិនសូវជាប្រញាប់ដើម្បីទៅធ្វើការនោះទេ ដោយសារតែគាត់សល់ម៉ោងច្រើនដែរ
អញ្ចឹងគាត់ដើរជាធម្មតា ដើរមិនប្រញាប់ប្រញាល់ ឬក៏មិនរត់នោះទេ បាទ ព្រោះថាប្រសិនបើយើងរត់
វាអាចនឹងបែកញើស បែកញើសប្រឡាក់ខោអាវ អញ្ចឹងវាធ្វើឲ្យយើងមានធុំក្លិនខ្លួន
នៅពេលដែលចូលក្នុងកន្លែងធ្វើការ ដូច្នេះ យើងគួរតែដើរតាមសម្រួល ប្រសិនបើយើងដើរទៅធ្វើការ
យើងគួរតែដើរតាមសម្រួល ដើម្បីកុំឲ្យវាបែកញើសនិងមានធុំក្លិនទៅលើអ្នកដទៃ។

ចូលដល់រូបភាពទី ១៧ អញ្ចឹងនៅក្នុងរូបភាពទី ១៧ បន្ទាប់ពីគាត់ដើរបានបន្តិចមក យើងឃើញថា
គាត់ក៏បានចូលទៅដល់កន្លែងធ្វើការរបស់គាត់។
អញ្ចឹងគាត់បានដើរមកដល់មុខកន្លែងធ្វើការរបស់គាត់ហើយ ដោយកន្លែងធ្វើការរបស់គាត់
គឺមានប្រើប្រាស់ទ្វារកញ្ចក់។ បាទ ប៉ុន្តែទ្វារនោះមិនបើកនោះទេ មិនមែនបានន័យថា
មិនទាន់ដល់ម៉ោងធ្វើការនោះទេ ក៏ប៉ុន្តែជាទូទៅទ្វារក្រុមហ៊ុនឬក៏ទ្វារកន្លែងធ្វើការ
គឺគេតែងតែបិទជានិច្ច ប៉ុន្តែគេមិនចាក់សោនោះទេ ដោយសារតែគេត្រូវបើកចេញចូលជាប្រចាំ
ដូច្នេះគេគ្រាន់តែបិទ ដើម្បីកុំឲ្យមានដីហុយចូល ឬក៏មានខ្យល់ចូលខ្លាំង អញ្ចឹងទ្វារកញ្ចក់
គឺអាចមើលឃើញនៅខាងក្នុង ដូច្នេះ ពេលដែលនារីនោះទៅដល់ គាត់ត្រូវបើកទ្វារកញ្ចក់
ដើម្បីចូលទៅក្នុងការិយាល័យឬក៏កន្លែងធ្វើការរបស់គាត់។ ជាមួយនឹងបាយ
ដែលគាត់យួរមកអម្បាញ់មិញ យើងឃើញថាគាត់នឹងញ៉ាំបាយពេលព្រឹកនោះ
នៅក្នុងកន្លែងធ្វើការរបស់គាត់ឬក៏នៅក្នុងការិយាល័យរបស់គាត់តែម្ដង បាទ
ព្រោះថាគាត់ត្រូវមកឲ្យដល់កន្លែងធ្វើការឲ្យទាន់ម៉ោង បន្ទាប់មក
គាត់ត្រូវស្រស់ស្រូបអាហារពេលព្រឹកមុននឹងគាត់ធ្វើការ
ព្រោះប្រសិនបើយើងមិនបានស្រស់ស្រូបអាហារពេលព្រឹកនោះទេ យើងនឹងពុំមានកម្លាំងគ្រប់គ្រាន់
ដើម្បីធ្វើការនោះទេ ព្រោះថាព្រឹកឡើងគឺយើងនឹងហេវ ឬក៏យើងនឹងឃ្លាន
ដូច្នេះយើងត្រូវញ៉ាំឲ្យបានឆ្អែតមុននឹងធ្វើការ ដូចនារីម្នាក់នេះ ទោះបីជាគាត់មិនមានពេលច្រើន

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

សម្រាប់ញ៉ាំអាហារពេលព្រឹកនៅកន្លែងលក់អាហារពេលព្រឹកក៏ដោយ
ក៏ប៉ុន្តែគាត់ក៏បានខ្ចប់អាហារពេលព្រឹក ដើម្បីមកញ៉ាំនៅកន្លែងធ្វើការផងដែរ។ អញ្ចឹងបានន័យថា
ឥឡូវនេះ គាត់មកដល់កន្លែងធ្វើការរបស់គាត់ហើយ
ហើយគាត់ក៏កំពុងតែដើរសំដៅចូលទៅក្នុងការិយាល័យរបស់គាត់ផងដែរ ដើម្បីធ្វើការរបស់គាត់
ដូចសព្វមួយដង ឬក៏ជាដូចរាល់ថ្ងៃអញ្ចឹងដែរ បាទ។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.